# I. ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រម

### ព្រះរាជក្រមលេខ ១០ នស ៩៤ ស្តីពីច្បាប់
### ថវិការបស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ប្រចាំឆ្នាំ១៩៩៥
### ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៤

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

យោងតាមមាត្រា ២៨ និង ៣០ ជំពូកទី២ ស្តីអំពី

ព្រះមហាក្សត្រ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រ កម្ពុជា ឆ្នាំ ១៩៩៣

**ប្រកាសអោយប្រើ**

ច្បាប់ស្តីពីថវិការបស់រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
ប្រចាំឆ្នាំ១៩៩៥ ដែលរដ្ឋសភាបានអនុម័ត ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ ១៩៩៤ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៤

ក្នុងព្រះបរមនាម និង តាមព្រះរាជបង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

# ច្បាប់

## ស្តីពី
## ថវិការបស់រដ្ឋសភា នៃ ព្រះរាជាណាចក្រកម្ពុជា
## ប្រចាំឆ្នាំ ១៩៩៥

### ជំពូកទី ១
### បទបញ្ញត្តិទូទៅ

មាត្រា ១ -

ថវិកាប្រចាំឆ្នាំ ១៩៩៥ របស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានបង្កើតឡើងដើម្បីទ្រទ្រង់សេវា និង សកម្មភាពទាំងឡាយរបស់តំណាងរាស្ត្រ និង មន្ត្រីរាជការ ទាំងអស់របស់អគ្គលេខាធិការដ្ឋាននៃរដ្ឋសភា ។

មាត្រា ២ -

ថវិកាប្រចាំឆ្នាំ ១៩៩៥ របស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាត្រូវបានរៀបចំនិងអនុវត្តដោយអនុលោមទៅតាមមាត្រា ៩១ នៃរដ្ឋធម្មនុញ្ញនិងតាមបទបញ្ញត្តិទាំង ឡាយនៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុនិងច្បាប់ស្តីពីហិរញ្ញវត្ថុជាធរមាន ។

មាត្រា ៣ -

ចំនួនក្របខ័ណ្ឌមន្ត្រីរាជការអគ្គលេខាធិការដ្ឋាននៃរដ្ឋសភា ត្រូវបានកំណត់សម្រាប់ឆ្នាំ ១៩៩៥ ត្រឹម ២៥០ កន្លែង ។

### ជំពូកទី ២
### ចំណូលនៃថវិការបស់រដ្ឋសភា

មាត្រា ៤ -

ចំណូលសរុប នៃថវិការបស់រដ្ឋសភា បានមកពីឥណទានចំណាយនៃថវិកា ទូទៅរបស់រដ្ឋប្រចាំឆ្នាំ ១៩៩៥ មានចំនួន ទឹក ប្រាក់សរុប ៩០៨០ លានរៀល ។

មាត្រា ៥ -

ចំណូលជាយថាហេតុរបស់រដ្ឋសភាដែលបានមកពីអំណោយ និង ជំនួយ ផ្សេង ៗ នៅក្នុងឬក្រៅប្រទេស ត្រូវបានចាត់ចែង និង ប្រើប្រាស់ដោយ រដ្ឋសភា ខ្លួនផ្ទាល់ ប៉ុន្តែត្រូវធ្វើ ទម្រង់បែបបទបញ្ចូលទៅក្នុងថវិកាជាតិ និង បញ្ចេញ មកវិញតាមបទ បញ្ញត្តិ នៃច្បាប់ ។

ជំពូកទី ៣

ឥណទានសម្រាប់ចំណាយក្នុងថវិការបស់រដ្ឋសភា

មាត្រា ៦ -

ឥណទានសរុបសម្រាប់ចំណាយក្នុងថវិកាប្រចាំឆ្នាំ ១៩៩៥ របស់រដ្ឋសភា មាន ចំនួន ៩០៨០ លានរៀល ។

មាត្រា ៧ -

ឥណទានដូចមានចែងក្នុងមាត្រា ៦ ខាងលើនេះត្រូវបានផ្តល់សម្រាប់ កិច្ច ប្រតិបត្តិការរបស់រដ្ឋសភាស្របតាមជំពូកនានានៃថវិកាជាតិ ។

ជំពូកទី ៤

អវសានបញ្ញត្តិ

មាត្រា ៨ -

ក្រោយពេលចូលជាធរមាន ច្បាប់នេះត្រូវបានបញ្ជូនទៅក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីបញ្ចូលថវិការដ្ឋសភាក្នុងថវិកាជាតិ ប្រចាំឆ្នាំ ១៩៩៥ ។

មាត្រា ៩ -

ច្បាប់នេះត្រូវបានប្រកាសទុកជាការប្រញាប់។ច្បាប់នេះត្រូវបាន រដ្ឋសភានៃ ព្រះរាជាណាចក្រកម្ពុជាអនុម័តនៅថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៤ នាសម័យប្រជុំ រដ្ឋសភាលើកទី ៣ នីតិកាលទី ១

ហត្ថលេខា និង ត្រា

ប្រធានរដ្ឋសភាស្តីទី

លូយ ស៊ីមឈាង